# បន្ទុកចំណាយបន្ថែមទាក់ទងនឹងពិការភាពនៅកម្ពុជា៖ ភាពប្រទាក់ក្រឡាសម្រាប់ការរៀបចំគម្រោងកិច្ចគាំពារសង្គម

## ១. សេចក្តីផ្តើម

**ជនមានពិការភាពត្រូវបានបង្ហាញឱ្យឃើញថាមានសមាមាត្រមិនស្មើគ្នាក្នុងចំណោមសមាជិកក្រីក្របំផុតនៃប្រជាជនក្នុងប្រទេសកម្ពុជា។** ជារួម អត្រានៃភាពក្រីក្រថ្នាក់ជាតិ (២០២១) ក្នុងចំណោមជនមិនមានពិការភាព គឺមាន១៧,៥ ភាគរយ ខណៈដែលមាន២១,១ ភាគរយក្នុងចំណោមជនមានពិការភាព។[1] ការស្ទង់មតិសេដ្ឋកិច្ចសង្គមកម្ពុជា (CSES, ២០១៩)[2] បានលើកឡើងថា ២៦ភាគរយនៃជនមានពិការភាពស្ថិតក្នុងក្រុមប្រជាជនក្រីក្របំផុត ខណៈដែលមានតែ១៣ភាគរយ ប៉ុណ្ណោះស្ថិតក្នុងក្រុមដែលមានជាងគេ។ ភាពខុសគ្នាខ្លាំងបំផុតនៃអត្រាភាពក្រីក្ររវាងជនមានពិការភាព និងជនមិនមានពិការភាពគឺក្នុងចំណោមកុមារដែលមានអាយុចន្លោះពី 0 ទៅ ១៧ ឆ្នាំ។

**រូបភាពទី១៖ សមាមាត្រជនមានពិការភាពនិងជនមិនមានពិការភាពដែលរស់នៅក្រោមបន្ទាត់ក្រីក្រ បែងចែកតាមក្រុមអាយុ**




ប្រភព៖ CSES 2019

---

[1] នេះគឺផ្អែកលើអត្រាភាពក្រីក្រថ្នាក់ជាតិដែលរៀបចំដោយដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ ២០២១ សូមមើលរបាយការណ៍របស់ធនាគារពិភពលោក **https://www.worldbank.org/en/country/cambodia/overview** (ចូលដំណើរការថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០២២)

[2] CSES. 2019.

ខែវិច្ឆិកា ឆ្នាំ២០២២

**គ្រួសារដែលមានជនមានពិការភាពក្នុងប្រទេសកម្ពុជាមានកម្រិតស្តង់ការនៃការរស់នៅទាប ជាមធ្យម បើប្រៀបធៀបទៅនឹងគ្រួសារផ្សេងទៀត។** ការចំណាយប្រចាំថ្ងៃជាមធ្យមសម្រាប់មនុស្សម្នាក់ៗនៃគ្រួសារដែលមានជនមានពិការភាពគឺ ១៤.៩០០ រៀងល (៣,៧០ដុល្លារអាមេរិក) ក្នុងឆ្នាំ ២០១៩ បើប្រៀបធៀបទៅនឹង ១៩.៣០០ រៀល (៤,៨០ ដុល្លារអាមេរិក) នៃគ្រួសារដែលមិនមានជនមានពិការភាព។[3]

**ប៉ុន្តែ ដោយសារតែ «ការចំណាយបន្ថែមទាក់ទងនឹងពិការភាព» ស្ថានភាពសេដ្ឋកិច្ចជាក់ស្តែងសម្រាប់ជនមានពិការភាព និងគ្រួសាររបស់ពួកគេ ជាក់ស្តែងគឺទាបជាងច្រើន** ដែលត្រូវបានលើកឡើងដោយតួលេខចំណាយ និងអត្រាភាពក្រីក្រ។ **នៅពេលរៀបចំប្រព័ន្ធកិច្ចគាំពារសង្គមសម្រាប់ជនមានពិការភាពប្រកបដោយបរិយាបន្ន វាមានសារៈសំខាន់ណាស់ក្នុងការគិតគូរពីការចំណាយបន្ថែមទាក់ទងនឹងពិការភាព**ដើម្បីឱ្យជនមានពិការភាពទទួលបានឱកាសស្មើគ្នាជាមួយសមាជិកដទៃទៀតនៅក្នុងសង្គមដែរ។

## ២. ទស្សនទាននៃការចំណាយទាក់ទងនឹងពិការភាព

ជនមានពិការភាពជួបប្រទះទៅនឹងទម្រង់សំខាន់ពីរយ៉ាងទាក់ទងការចំណាយបន្ថែម៖

ក. **ជារឿយៗ ពួកគេតម្រូវឱ្យទិញឬមានគ្រឿងសម្ភារ និងសេវាកម្មដែលជាក់លាក់ចំពោះពិការភាពរបស់ពួកគេ។** ឧទាហរណ៍ ឧបករណ៍ជំនួយ សេវា ស្តារលទ្ធភាពពលកម្មកាយសម្បទា តម្រូវការការ ថែទាំ និង ថ្នាំសង្កូវជាដើម។

. **សម្រាប់ការទិញគ្រឿងសម្ភារនិងប្រើប្រាស់សេវាកម្មផ្សេងៗដែលជនមិនមានពិការភាពក៏អាចប្រើប្រាស់បានដែរនោះ ជនមានពិការអាចតម្រូវអោយមានការចំណាយបន្ថែម។** ឧទាហរណ៍ មនុស្សដែលជិះលើរទេះរុញអាចយល់ថា វាមិនអាចទៅរួចទេក្នុងការធ្វើដំណើរតាមមធ្យោបាយដឹកជញ្ជូនសាធារណៈហើយជាលទ្ធផលប្រហែលជាត្រូវប្រើតាក់ស៊ីដែលមានតម្លៃថ្លៃជាង និង បង់ប្រាក់សម្រាប់អ្នកផ្តល់ជំនួយក្នុងការជួយសម្របសម្រួលការធ្វើដំណើររបស់ពួកគាត់។

**ប្រអប់ទី១៖ការចំណាយបន្ថែមក្នុងការទទួលបានសេវាសុខ ភាពសំខាន់ៗ និងសេវាផ្សេងទៀត «បទពិសោធន៍របស់ស្ត្រី និងកុមារមានពិការភាពនៅក្នុងប្រទេសកម្ពុជា»**

ការអង្កេតបែបគុណវិស័យធ្វើឡើងដោយ ACCESS (2022) បានរកឃើញថា ស្ត្រីមានពិការភាពភាគច្រើន (២២នាក់ក្នុងចំណោម ២៩ នាក់ដែលត្រូវបានសម្ភាស) ត្រូវសុំលុយពីប្តី ឬឪពុកម្តាយ ឬបងប្អូនរបស់ពួកគេ ដើម្បីទៅរកសេវាថែទាំសុខភាព ឬសេវាផ្សេង ទៀត។ ស្ត្រីទាំងនេះបានរាយការណ៍ថា ប្រសិនបើពួកគេមានលុយផ្ទាល់ខ្លួនពួកគេអាចទទួលបានការថែទាំសុខភាពកាន់តែងាយ ស្រួល។

"វាពិបាកក្នុងការរកនរណាម្នាក់ទៅជាមួយខ្ញុំទៅកាន់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា (PRC)។ ខ្ញុំមានបងប្អូនប្រុសស្រី ប៉ុន្តែខ្ញុំត្រូវឱ្យលុយពួកគេ [ដើម្បីដឹកខ្ញុំទៅទីនោះ]"។ (ស្ត្រីមានពិការភាពដែលបានសម្ភាស)

"សមាជិកគ្រួសាររីករាយក្នុងការបញ្ជូនកូនៗរបស់ពួកគេទៅមន្ទីរពេទ្យលើកទីមួយ ឬលើកទីពីរ។ ប៉ុន្តែ នៅពេលពួកគាត់ដឹងថា ពួកគាត់ត្រូវចំណាយថវិកាអស់ច្រើនហើយនោះ ពួកគាត់នឹងមិនបញ្ជូនពួកគេទៅទៀតទេ"។ (អ្នកតំណាង OPD)

**ការចំណាយបន្ថែមទាំងនេះបានធ្វើឲ្យប៉ះពាល់ដល់កម្រិតជីវភាពរស់នៅរបស់គ្រួសារដែលមានសមាជិកមានពិការភាព** នេះ បើប្រៀបធៀបទៅនឹងគ្រួសារផ្សេងទៀតដែលមានប្រាក់ចំណូលនិងការចំណាយប្រហាក់ប្រហែល គ្នា។ **ស្ត្រីនៅក្នុងគ្រួសារជាពិសេសស្ត្រីមានពិការភាពតែងតែជួបប្រទះឧបសគ្គបន្ថែមក្នុងការទទួលបានប្រាក់ចំណូល និងក្នុងការធ្វើការសម្រេចចិត្តក្នុងការចំណាយផ្សេងៗក្នុងគ្រួសារ។** ហើយនេះជាកត្តាដែលកាត់បន្ថយសិទ្ធិអំណាចដែលពួកគេត្រូវការដើម្បីធ្វើការសម្រេចចិត្តអំពីអាទិភាពចំណាយផ្សេងៗទៅលើសេវាកម្មនិងគ្រឿងសម្ភារផ្សេងៗដែលពួកគេ ឬកូនៗរបស់ពួកគេត្រូវការ។ "ជាការពិតណាស់ នៅក្នុងគ្រួសារ ស្ត្រីនិងកុមារមានពិការភាពមិនទទួលបានការមើលថែល្អគ្រប់គ្រាន់នោះទេ។ ជារឿយៗ ពួកគេត្រូវបានគេរើសអើង ហើយសមាជិកគ្រួសារផ្សេងទៀតមានអារម្មណ៍ថា ជនមានពិការភាពគឺជាបន្ទុកបន្ថែម។

---

[3]CSES, 2019.

នេះគឺដោយសារពួកគេត្រូវលះបង់ឱកាសក្នុងការប្រកបរបរចិញ្ចឹមជីវិត មានអាជីវកម្មនិងការងារផ្សេងទៀត ដើម្បីមើលថែសមាជិកគ្រួសារដែលមានពិការភាព»។ តំណាង អង្គការតំណាងជនមានពិការភាព **ក្របខ័ណ្ឌទស្សនទាន** (រូបភាពទី២) បង្ហាញពីប្រភេទនៃការចំណាយរបស់ជនមានពិការភាព និងគ្រួសារដែលមានជនមានពិការភាពរស់នៅជាមួយ បើប្រៀបធៀបជាមួយបុគ្គលនិងគ្រួសារដែលមិនមានជនមានពិការភាព។

## រូបភាពទី២៖ ក្របខ័ណ្ឌទស្សនទាន - ការចំណាយបន្ថែមទាក់ទងនឹងពិការភាព




**ទិន្នន័យនិងភស្តុតាងជាអន្តរជាតិបានបង្ហាញថាការចំណាយបន្ថែមទាំងនេះអាចមានចំនួនច្រើនសន្ធឹកសន្ធាប់។**នៅក្នុងប្រទេសមួយចំនួន ការចំណាយបន្ថែមត្រូវបានប៉ាន់ប្រមាណថា មានការបន្ថែម ១០ ភាគរយនៃការចំណាយសរុបក្នុងគ្រួសារ ខណៈដែលប្រទេសផ្សេងទៀតត្រូវបានប៉ាន់ប្រមាណថា មានច្រើនជាង ៥០ ភាគរយ។[4] លើសពីនេះ ទាក់ទងនឹងការចំណាយជាមធ្យមប្រចាំគ្រួសារ៖ គ្រួសារនីមួយៗអាចមានការចំណាយទាក់ទងនឹងពិការភាពដែលអាចខ្ពស់ជាងច្រើន។

### ប្រអប់ទី២៖ វិធីសាស្រ្តកម្រិតស្តង់ដារនៃការរស់នៅ (SOL) សម្រាប់ការគណនាការចំណាយបន្ថែមទាក់ទងនឹងពិការភាព

វិធីសាស្រ្ត SOL គឺផ្អែកលើទស្សនទាននៃការប្រែប្រួលការទូទាត់សំណង ហើយប៉ាន់ស្មានធនធានបន្ថែមដែលត្រូវការសម្រាប់គ្រួសារដែលមានសមាជិកពិការភាពដើម្បីឈានទៅដល់កម្រិតស្តង់ដារនៃការរស់នៅដូចគ្នាទៅនឹងគ្រួសារស្រដៀងគ្នាផ្សេងទៀតដែលមិនមានសមាជិកពិការភាព។ ការចំណាយបន្ថែមទាក់ទងនឹងពិការភាពត្រូវបានបញ្ជាក់ថាសំខាន់ ដោយសារត្រូវការប្រាក់ចំណូលបន្ថែមក្នុងរយៈពេលដែលទាក់ទងគ្នាសម្រាប់គ្រួសារដែលមានសមាជិកមានពិការភាព បើប្រៀបធៀបទៅនឹងគ្រួសារស្រដៀងគ្នាដែលមិនមានសមាជិកមានពិការភាពដើម្បីទទួលបានកម្រិតស្តង់ដារនៃការរស់នៅដូចគ្នា។

**ដើម្បីទទួលបាននូវកម្រិតស្តង់ដារនៃការរស់នៅដូចគ្នានឹងគ្រួសារផ្សេងទៀត គ្រួសារដែលមានជនមានពិការភាពត្រូវការប្រាក់ចំណូលបន្ថែម។**ដូច្នេះហើយនៅពេលដែលគ្រួសារពីរមានការចំណាយក្នុងមនុស្សម្នាក់ដូច គ្នា គ្រួសារដែលមានជនមានពិការភាពនឹងមានកម្រិតស្តង់ដារនៃការរស់នៅជីវភាពទាបជាង ដោយសារតែសមាមាត្រនៃការចំណាយរបស់ពួកគេបានប្រើប្រាស់ទៅលើការចំណាយបន្ថែមទាក់ទងនឹងពិការភាព។ លើសពីនេះ មនុស្សជាច្រើនដែលមានប្រាក់ចំណូលទាប មិនអាចលៃលកសម្រាប់ការចំណាយបន្ថែមសម្រាប់សមាជិកដែលមានពិការភាពទេ ដែលជាហេតុនាំអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់គុណភាពជីវិតរបស់ពួកគេរួមទាំងជនមានពិការភាព។ **ផលវិបាកមួយនៃការចំណាយបន្ថែមទាក់ទងនឹងពិការភាពគឺថា អត្រានៃភាពក្រីក្រសម្រាប់គ្រួសារមួយចំនួន រួមទាំងជនមានពិការភាពត្រូវបានគេប៉ាន់ស្មានមិនបានត្រឹមត្រូវ** លុះត្រាតែវាត្រូវបានកែសម្រួលដើម្បីគិតគូរពីការចំណាយបន្ថែម។

## ៣.   ការចំណាយបន្ថែមទាក់ទងនឹងពិការភាពនៅក្នុងប្រទេសកម្ពុជា

**ការវិភាគទិន្នន័យបន្ថែមប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គមនៅកម្ពុជាផ្តល់នូវភស្តុតាងនៃការចំណាយផ្ទាល់ និងដោយប្រយោលជាច្រើនសម្រាប់ជនមានពិការភាព និងគ្រួសាររបស់ពួកគេ។**

### ទិន្នន័យនិងភស្តុតាងនៃការចំណាយដោយផ្ទាល់៖

**កុមារដែលមានពិការភាពនៅកម្ពុជាទំនងជា (១៦ភាគរយ)មានជំងឺឬឈឺ ច្រើនជាងកុមារដែលមិនមានពិការភាព (៨ភាគរយ)។** ជំងឺ ឬរបួសទំនងអាចមានសភាពធ្ងន់ធ្ងរជាងកុមារមិនមានពិការភាព។ ឧទាហរណ៍ កុមារមិនមានពិការភាពត្រឹមតែ១ភាគរយប៉ុណ្ណោះដែលមានជំងឺ ឬរបួសធ្ងន់ធ្ងរ បើប្រៀបធៀបទៅនឹង ៧ភាគរយនៃកុមារមានពិការភាព (DHS ២០១៤)។ **ជនមានពិការភាពចំណាយជាមធ្យម ៣៩ ភាគរយលើការថែទាំសុខភាព** (ការព្យាបាល និងការធ្វើដំណើរ) ច្រើនជាងជនមិនមានពិការភាព (រូបភាពទី៥)។

**ជនមានពិការភាពក្នុងវ័យធ្វើការងារគឺងាយនឹងមានជំងឺ** ដែលអាចប៉ះពាល់ដល់សមត្ថភាពរកប្រាក់ចំណូលរបស់ពួកគេផងដែរ៖ ក្នុងឆ្នាំ ២០១៩ គឺ ៤១ ភាគរយនៃមនុស្សពេញវ័យក្នុងវ័យធ្វើការងារដែលមានពិការភាពបានជួប ប្រទះនឹងជំងឺ ឬរបួសក្នុងរយៈពេល៣០ថ្ងៃកន្លងមកនេះ បើប្រៀបធៀបទៅនឹង ១២ភាគរយនៃមនុស្សពេញវ័យដែលមិនមានពិការភាព។ ស្ត្រី ៤៧ ភាគរយ ទំនងជាធ្លាក់ខ្លួនឈឺច្រើនជាងបុរស ដែលមានតែ៣៦ ភាគរយ ផ្អែកលើជំរឿន ២០១៩។

**រូបភាពទី៣៖ ការប្រៀបធៀបការចំណាយលើសុខភាពប្រចាំខែជាមធ្យមរវាងជនមានពិការភាព និងជនមិនមានពិការភាពតាមក្រុមអាយុ[5]**




ប្រភព៖ CSES 2019[6].

### ទិន្នន័យនិងភស្តុតាងនៃការចំណាយដោយប្រយោល

**៣៧ភាគរយនៃកុមារដែលមានអាយុលើសពី៥ឆ្នាំដែលមានពិការភាពមិនដែលបានចូលសាលាទេ** បើប្រៀបធៀបទៅនឹង៦ភាគរយនៃកុមារដែលមិនមានពិការភាព។ បើទោះជាមានហេតុផលជាច្រើនសម្រាប់ការមិនបានចូលសាលាក៏ដោយ ក៏ការចំណាយទំនងជាហេតុផលមួយដែរ។ (ជំរឿន ២០១៩)

**កម្រិតនៃកុមារមានពិការភាពដែលទំនងជាបោះបង់ការសិក្សាមានជិតពីរដង** (១៥ ភាគរយ ធៀបនឹង៨ភាគរយ) បើប្រៀបធៀបទៅនឹងកុមារដែលមិនមានពិការភាព និងការមិនបានចូលសាលារបស់កុមារមានពិការភាពនៅតំបន់ជនបទ (៤០ ភាគរយ) ខ្ពស់ជាងតំបន់ទីក្រុង (៣២ ភាគរយ)។ (ជំរឿន ២០១៩)

**ការរាតត្បាតនៃជំងឺកូវីដ-១៩** បានរួមចំណែកបន្ថែមទៀតចំពោះកុមារមានពិការភាពជាច្រើននាក់ដែលមកពីគ្រួសារក្រីក្រ និងគ្រួសារនៅជនបទកាន់តែច្រើនឡើងមិនអាចទទួលបានការសិក្សាដែលបានផ្តល់តាមរយៈវិធីសាស្ត្រសិក្សាពីចម្ងាយ។ (អ្នកតំណាង OPD) **ជនមានពិការភាពទំនងជាមិនសូវទទួលបានការងារធ្វើនៅក្នុងវដ្តជីវិតរបស់ពួកគេទេ។**

---

[5] ភាពខុសគ្នាមិនមានភាពធំធេង បើផ្អែកតាមទិន្នន័យ

[6] ការប៉ាន់ប្រមាណជាពិសេសសម្រាប់កុមារគួរត្រូវបានព្យាបាលដោយប្រុងប្រយ័ត្ន ដោយសារទំហំគំរូតូច និងកម្រិតនៃសារៈសំខាន់តាមស្ថិតិ។

## រូបភាពទី ៤ និងទី៥៖ ការងារនៅក្នុងវដ្តជីវិតដោយស្ថានភាពពិការភាព និងប្រាក់ចំណូលគ្រួសារជាមធ្យម សម្រាប់មនុស្សម្នាក់ៗដោយការមានសមាជិកមានពិការភាព (CSES ២០១៩)







**ភាពខុសគ្នានៃឱកាសការងាររវាងជនមានពិការភាព និងជនមិនមានពិការភាព បណ្តាលអោយមានប្រាក់ចំណូលខុសគ្នា៖** ប្រាក់ចំណូលជាមធ្យមក្នុងចំណោមជនមិនមានពិការភាពទាក់ទងការងារគឺ ១.០៨០.១០០ រៀល (២៦៧ដុល្លារអាមេរិក) ក្នុងមួយខែ បើប្រៀបធៀបទៅនឹង ៧១៥.០០០ រៀល (១៧៧ ដុល្លារអាមេរិក) ក្នុងមួយខែក្នុងចំណោមជនមានពិការភាព។

**៤៨ភាគរយនៃស្ត្រីក្នុងវ័យធ្វើការងារដែលមានពិការភាពមិនស្ថិតក្នុងទម្រង់ការងារណាមួយទេ ខណៈដែល១១ ភាគរយធ្វើការងារសម្រាប់គ្រួសារដែលមិនមានប្រាក់ខែ (ជំរឿន ២០១៩)**។ ការងារដែលមិនមានប្រាក់ខែទាំងនេះទំនងជាមានការងារផ្ទះនិងសកម្មភាពក្នុងគ្រួសារផ្សេងទៀត។ ការមិនមានប្រភពសាច់ប្រាក់ឯករាជ្យ អាចបណ្តាលអោយការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងគ្រួសាររបស់ស្ត្រីមានពិការភាពជាច្រើននៅមានកម្រិត។លើសពីនេះទៀតពួកគេនឹងមានទ្រព្យធនធានតិចជាងបុរស។

## ការចំណាយដែលប៉ាន់ស្មាន

ការសិក្សាដ៏ទូលំទូលាយដែលធ្វើឡើងក្នុងឆ្នាំ២០១៩បានរកឃើញថា គ្រួសារដែលមានជនមានពិការភាពនៅក្នុងប្រទេសកម្ពុជាជាមធ្យមត្រូវការ**ចំណូលបន្ថែម ១៨,៦ភាគរយ (តំណាងដោយការចំណាយ) ដើម្បីឈានដល់កម្រិតស្តង់ដារនៃការរស់នៅដូចគ្នានឹងគ្រួសារស្រដៀងគ្នាផ្សេងទៀតដែលមិនមានសមាជិកមានពិការភាព**។[7]
ការសិក្សានេះក៏បង្ហាញផងដែរថា ការចំណាយបន្ថែមដែលទាក់ទងនឹងជនមានពិការភាពប្រែប្រួលនៅក្នុងវដ្តជីវិតទាំងមូល ។ **ផលប៉ះពាល់នៃការចំណាយបន្ថែមទាក់ទងនឹងពិការភាពស្តីពីកម្រិតស្តង់ដារនៃការរស់**នៅត្រូវបានបង្ហាញក្នុងរូបភាពទី៦។ ដោយផ្អែកលើប្រាក់ចំណូលជាមធ្យមក្នុងប្រទេសកម្ពុជាចំនួន ៧៥.៤០០ រៀល (១៩ដុល្លារអាមេរិក) ក្នុងមួយថ្ងៃ (ពីCSES ២០១៩) គ្រួសារដែលមានសមាជិកមានពិការភាពនឹងត្រូវការប្រាក់បន្ថែមចំនួន១៤.០០០ រៀល (៣,៥០ ដុល្លារអាមេរិក) ក្នុងមួយថ្ងៃដើម្បីរក្សាកម្រិតស្តង់ដារនៃការរស់នៅដូចគ្នានឹងគ្រួសារដែលមិនមានសមាជិកមានពិការភាព។[8]

| ប្រអប់ទី៣៖ភាគរយនៃការចំណាយក្នុងគ្រួសារសម្រាប់ជនមានពិការភាព | ភាគរយនៃការចំណាយក្នុងគ្រួសារ |
|---|---|
| សមាជិកផ្សេងៗទៀតដែលមានពិការភាព | 18.6 |
| កុមារក្រោមអាយុ២០ឆ្នាំដែលមានពិការភាព | 21.7 |
| មនុស្សពេញវ័យធ្វើការអាយុចន្លោះពី២០ទៅ៥៩ឆ្នាំដែលមានពិការភាព | 15.4 |
| ជនចាស់ជរាមានពិការភាពដែលមានអាយុលើសពី៦០ឆ្នាំ | 18.2 |

[7] Palmer et al (2019) ទិនានុប្បវត្តិនៃការសិក្សាអភិវឌ្ឍន៍, ២០១៩, ច្បាប់ ៥៥, លេខ ១១, ២៣៨២-២៤០២
[8] ប្រសិនបើប្រាក់ចំណូលជាមធ្យមត្រូវបានប្រើប្រាស់ ការចំណាយបន្ថែមនឹងមានចំនួន ១០,១០០ រៀល (២,៥ដុល្លារអាមេរិក) ក្នុងមួយថ្ងៃ។

## រូបភាពទី ៦៖ ការរក្សាឱ្យបាននូវជីវភាពរស់នៅដូចគ្នារវាងគ្រួសារដែលមាន និងគ្មានសមាជិកមានពិការភាព។




ប្រភព៖ ការវិភាគដោយផ្ទាល់ Development Pathways

**ប្រាក់បន្ថែមចំនួន ១៤.០០០ រៀលក្នុងមួយថ្ងៃគឺជាតម្រូវការប្រាក់ចំណូលបន្ថែមដ៏ច្រើនសម្រាប់គ្រួសារជាមធ្យមដែលមានជនមានពិការភាព** ដែលត្រូវការដើម្បីរក្សាកម្រិតស្តង់ដារនៃការរស់នៅដូចគ្រួសារដែលមិនមានជនមានពិការភាព។ សម្រាប់ជនមានពិការភាពជាច្រើននិងសមាជិកគ្រួសាររបស់ពួកគេវាមានហានិភ័យយ៉ាងខ្លាំងអំពីអសន្តិសុខប្រាក់ចំណូលនិងភាពក្រីក្រជាសំខាន់។

ប្រសិនបើការចំណាយបន្ថែមជាមធ្យមចំនួន ១៤.០០០ រៀលក្នុងមួយថ្ងៃសម្រាប់ជនមានពិការភាពត្រូវបានអនុវត្តចំពោះការបែងចែកលើសុខុមាលភាព វាបង្ហាញថា ជនមានពិការភាពដែលរស់នៅក្នុងក្រុមក្រីក្របំផុតមិនអាចរ៉ាប់រងលើការចំណាយបន្ថែមទាំងនេះបានទេ។ ជាមធ្យម ការចំណាយបន្ថែមមាន ១២៨ ភាគរយនៃប្រាក់ចំណូលគ្រួសារប្រចាំថ្ងៃរបស់ពួកគាត់។

### ប្រអប់ទី៤៖ឧទាហរណ៍អំពីការចំណាយបន្ថែម-តម្រូវការថែទាំសុខភាពនិងការស្តារនីតិសម្បទាសម្រាប់ជនមានពិការភាព

នៅក្នុងគ្រួសារដែលមានជនមានពិការភាព ការចំណាយជាមធ្យមលើសុខភាពគឺ២៧០.១០០ រៀលក្នុងមួយខែ បើប្រៀប ធៀបទៅនឹង ១៩៤.៦០០រៀលក្នុងគ្រួសារផ្សេងទៀតដែលមិនមានជនមានពិការភាព (សូមមើលរូបភាព ៤)។ ការវិភាគរបស់យើងបង្ហាញថា ភាពខុសគ្នាដ៏ធំបំផុតគឺក្នុងចំណោមកុមារ ដែលការចំណាយគឺខ្ពស់ជាងច្រើន (ទោះបីជាទិន្នន័យមិនមានភាពខុសគ្នាខ្លាំងក៏ដោយ) ។ ការបំពេញតាមការចំណាយបន្ថែមលើសុខភាពអាចមានផលប៉ះពាល់អវិជ្ជមានដល់កម្រិតស្តង់ដារនៃការរស់នៅរបស់គ្រួសារ។ប្រសិនបើគ្រួសារមិនអាចបំពេញតាមការចំណាយទាំងនេះបានជំងឺនិងស្ថានភាពរបស់ជនមានពិការភាពអាចនឹងកាន់តែធ្ងន់ធ្ងរ ហើយវដ្តនៃភាពក្រីក្រទំនងជានឹងបន្តកើតមានជាបន្តរហូត។

នៅពេលដែលការចំណាយបន្ថែមទាក់ទងនឹងពិការភាពនៅក្នុងប្រទេសកម្ពុជាត្រូវបានយកមកពិចារណា អត្រានៃភាពក្រីក្រ "ពិតប្រាកដ" របស់ជនមានពិការភាពកាន់តែយ៉ាប់យ៉ឺនគួរឱ្យកត់សម្គាល់។ ការគណនាដែលធ្វើឡើងដោយផ្អែកលើទិន្នន័យ CSES ឆ្នាំ ២០១៩ បង្ហាញថា អត្រានៃភាពក្រីក្ររបស់ជនមានពិការភាពកើនឡើងពី ២១,១ ភាគរយ ដល់ ២៤,៣ ភាគរយ នៅពេលដែលការចំណាយបន្ថែមទាក់ទងនឹងពិការភាពត្រូវបានលើកយកមកពិចារណា។[9]


អាសយដ្ឋាន៖ អគារលេខ២៤០ ជាន់ទី៣ អគារ អានីណា ផ្លូវ២៧១
សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (៨៥៥) ១២ ៨៧៦ ៥៤៩
អ៊ីម៉ែល៖ info@accesscambodia.org
វេបសាយ៖ www.accesscambodia.org

## ៤. ផលប៉ះពាល់នៃការចំណាយទាក់ទងនឹងពិការភាពសម្រាប់ការរៀបចំប្រព័ន្ធកិច្ចគាំពារសង្គម

### បទពិសោធន៍ពីអន្តរជាតិ

**ប្រព័ន្ធកិច្ចគាំពារសង្គមសម្រាប់ជនមានពិការភាពប្រកបបរិយាបន្ននិងសមធម៌គឺជាប្រព័ន្ធមួយដែលគិតគូរពីការចំណាយបន្ថែមទាក់ទងនឹងពិការភាព** ដើម្បីផ្តល់លទ្ធភាពដល់ជនមានពិការភាពទាំងអស់អាចទទួលបានឱកាសនិងកម្រិតស្តង់ដារនៃការរស់នៅស្មើភាពគ្នាជាមួយជនមិនមានពិការភាព។ប្រព័ន្ធកិច្ចគាំពារសង្គមសម្រាប់ជនមានពិការភាពប្រកបដោយបរិយាបន្នដ៏ល្អផ្អែកលើបទពិសោធន៍ជាសាកលត្រូវបានបង្ហាញក្នុងរូបភាពទី៧។វានឹងផ្តល់អត្ថប្រយោជន៍ពិសេសសម្រាប់ជនមានពិការភាពនៅក្នុងវដ្តជីវិតទាំងមូលពីកុមារភាពដល់មនុស្សវ័យចំណាស់ដែលមានពិការភាព។ វានឹងរួមមាន៖

ក. **អត្ថប្រយោជន៍ដែលដោះស្រាយជាពិសេសសម្រាប់ការចំណាយទាក់ទងនឹងពិការភាព៖**

- **អត្ថប្រយោជន៍សម្រាប់ កុមារមានពិការភាពដើម្បីរ៉ាប់រងការចំណាយបន្ថែមដល់គ្រួសារសម្រាប់ការថែទាំកុមារដែលមានពិការភាព**ដែលអាចរួមបញ្ចូលប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កុមារមានពិការភាពក្នុងការទៅសាលារៀន
- ការទូទាត់សម្រាប់ភាពឯករាជ្យបុគ្គល (PIP), ដែលនឹងរ៉ាប់រងលើការចំណាយបន្ថែមទាក់ទងនឹងពិការភាពដែលជួបប្រទះដោយមនុស្សពេញវ័យដែលមានពិការភាព

ខ. **អត្ថប្រយោជន៍ដែលផ្តល់ជាប្រាក់ចំណូលដល់បុគ្គល និង/ឬអ្នកថែទាំជនមានពិការភាព៖**

- **សោធននិវត្តន៍សម្រាប់ជនមានពិការភាព**ផ្តល់ជូនដល់មនុស្សពេញវ័យក្នុងវ័យធ្វើការងារ ដែលមិនអាចធ្វើការបានដោយសារតែពិការភាពរបស់ពួកគេ
- **ប្រាក់សោធននិវត្តន៍សម្រាប់មនុស្សវ័យចំណាស់**សម្រាប់មនុស្សចាស់ទាំងអស់ រួមទាំងជនមានពិការភាព
- **អត្ថប្រយោជន៍របស់អ្នកថែទាំ**សម្រាប់អ្នកដែលផ្តល់ការថែទាំដល់ជនមានពិការភាពកម្រិតធ្ងន់ធ្ងរ ហើយក្នុងស្ថានភាពខ្លះចំណូលរបស់ពួកគេត្រូវបានកាត់បន្ថយ ឬគ្មានប្រាក់ចំណូល ដោយសារតួនាទីថែទាំដែលពួកគេបំពេញ

**រូបភាពទី ៧៖ ប្រព័ន្ធកិច្ចគាំពារសង្គមដ៏ល្អពិសេសសម្រាប់ជនមានពិការភាព**




**ការទូទាត់ឯករាជ្យបុគ្គល ( PIP ) រហូតមកដល់បច្ចុប្បន្ន ទើបត្រូវបានណែនាំនៅក្នុងប្រទេសដែលមានចំណូលខ្ពស់តែប៉ុណ្ណោះ។** ស្ទើរតែគ្មានឧទាហរណ៍អំពីគម្រោងកិច្ចគាំពារសង្គមនៅក្នុងប្រទេសដែលមានប្រាក់ចំណូលមធ្យមដែលផ្តល់ទម្រង់នៃអត្ថប្រយោជន៍នេះទេ។ មូលហេតុគឺដោយសារតែវាទាមទារយន្តការវាយតម្លៃពិការភាពបែបទំនើប និងសមត្ថភាពរដ្ឋបាលដ៏រឹងមាំ។ ផ្ទុយទៅវិញ ប្រទេសដែលមានប្រាក់ចំណូលមធ្យមបានជ្រើសរើសសម្រាប់ជម្រើសសាមញ្ញជាងនេះ ប៉ុន្តែជាទូទៅជាជម្រើសមិនសូវមានប្រសិទ្ធភាពដែលផ្អែកលើតម្លៃនៃការផ្ទេរស្របតាមភាពធ្ងន់ធ្ងរនៃពិការភាព។ កត្តាកំណត់នៃជម្រើសនេះគឺថា ពិការភាពធ្ងន់ធ្ងរជាងនេះ តែងតែមិនជាប់ទាក់ទងនឹងការចំណាយខ្ពស់ទាក់ទងនឹងពិការភាពនោះទេ។

---

9 ការគណនាដែលធ្វើឡើងដោយអង្គ Development Pathways (២០២២) ក្នុងកិច្ចគាំពារសង្គម - ការវិភាគស្ថានភាពរបស់ជនមានពិការភាពនៅកម្ពុជា

## ជម្រើសដែលត្រូវពិចារណាក្នុងបរិបទកម្ពុជា

នៅក្នុងបរិបទបច្ចុប្បន្ននៃគម្រោងជំនួយសង្គមដែលផ្តោតលើភាពក្រីក្រ វាអាចធ្វើទៅបានដើម្បីធ្វើការកែតម្រូវដែលនឹងធានាថា ការចំណាយបន្ថែមដែលប្រើប្រាស់ដោយជនមានពិការភាព និងគ្រួសារដែលមានជនមានពិការភាពរស់នៅជាមួយ ត្រូវបានលើកយកមកពិចារណា។ កំណែទម្រង់សំខាន់ៗដែលកំពុងដំណើរការ - វិធីសាស្ត្រ proxy means test (PMT) លើការកំណត់ប័ណ្ណក្រីក្រ (IDPoor) ដែលត្រូវបានកែសម្រួល ដោយពិចារណាលើជនមានពិការភាពក្នុងចំណោមកត្តាងាយរងគ្រោះផ្សេងទៀត និងការណែនាំអំពីការរៀបចំជាកញ្ចប់គ្រួសារថ្មីដែលនឹងពិចារណាលើប្រាក់ឧបត្ថម្ភពិការភាពពេញមួយជីវិតសម្រាប់ជនមានពិការភាព-បង្កើតឱកាសសម្រាប់ដោះស្រាយការចំណាយបន្ថែមដែលជនមានពិការភាព និងក្រុមគ្រួសាររបស់ពួកគេបានជួបប្រទះ។ ការពិតទាក់ទងផលប៉ះពាល់នៃការចំណាយ និងឧបសគ្គក្នុងការណែនាំអំពីអត្ថប្រយោជន៍ហិរញ្ញប្បទានរបស់រដ្ឋដែលឆ្លើយតបនឹងការចំណាយបន្ថែមដែលជនមានពិការភាពនិងគ្រួសាររបស់ពួកគេបានជួបប្រទះ ត្រូវបានទទួលស្គាល់។

**ការចំណាយបន្ថែមទាក់ទងនឹងពិការភាពនៅកម្ពុជាអាចឆ្លុះបញ្ចាំងតាមរយៈ៖**

- **តម្លៃថេរអត្ថប្រយោជន៍ប្រាក់ឧបត្ថម្ភសម្រាប់ពិការភាព**។ ប្រសិនបើការទូទាត់ឯករាជ្យបុគ្គលត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា ដែលវាប៉ាន់ស្មានត្រឹមត្រូវនូវការចំណាយបន្ថែមដែលគ្រួសាររបស់ពួកគាត់បានជួបប្រទះ។ **តម្លៃដ៏ល្អនៃអត្ថប្រយោជន៍** ផ្អែកលើការវាយតម្លៃដែលបានអនុវត្ត និងបានចែករំលែកខាងលើគឺ **១០៦ ដុល្លារអាមេរិកក្នុងមួយខែ**។ ដោយពិចារណាពីទំហំសារពើពន្ធមានកំណត់ និងទន្ទឹមនឹងការគិតគូរអំពីតម្លៃគោលដៅដ៏ល្អដែលបានរៀបរាប់ខាងលើ។ ជំហានជាក់ស្តែងមួយចំនួនឆ្ពោះទៅរកការដោះស្រាយការចំណាយបន្ថែមទាក់ទងនឹងពិការភាពអាចត្រូវបានពិចារណាលើអត្ថប្រយោជន៍ជាទឹកប្រាក់ចំនួន ៨១.១០០ រៀលក្នុងមួយខែ (២០ដុល្លារអាមេរិក) សម្រាប់ជនមានពិការភាពធ្ងន់ធ្ងរ និង ៤០.៥០០ រៀល (១០ដុល្លារអាមេរិក) សម្រាប់ជនមានពិការភាពកម្រិតមធ្យម។
- **ដំណើរការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ**។ បច្ចុប្បន្នប័ណ្ណក្រីក្រមិនយកមកគិតសម្រាប់ការចំណាយបន្ថែមទាក់ទងនឹងពិការភាពដែលមានកម្រិតសិទ្ធិទទួលបានប្រាក់ចំណូលដូចគ្នាដែលត្រូវបានប្រើសម្រាប់ទាំងជនមានពិការភាព និងជនមិនមានពិការភាព។ នៅពេលដែល ប័ណ្ណក្រីក្រប្រើវិធីសាស្ត្រ proxy means test (PMT) មធ្យោបាយមួយស្តីពីការកែតម្រូវយន្តការកំណត់គោលដៅដើម្បីដាក់បញ្ចូលការចំណាយបន្ថែមសម្រាប់ជនមានពិការភាពគឺដើម្បីកែតម្រូវកម្រិតសិទ្ធិទទួលបានសម្រាប់គ្រួសារដែលមានជនមានពិការភាពដើម្បីជួយធានាថា ការកំណត់គោលដៅកាន់តែត្រឹមត្រូវ ហើយការរួមបញ្ចូលជនមានពិការភាព ត្រូវបានដាក់បញ្ចូលទៅក្នុងគម្រោងនេះ។

# ៥. សេចក្តីសន្និដ្ឋាន

ជនមានពិការភាពប្រឈមនឹង"ការចំណាយទាក់ទងនឹងពិការភាព"ដែលកាត់បន្ថយកម្រិតស្តង់ដារនៃការរស់នៅរបស់ពួកគេ។ សម្រាប់សមភាពកម្រិតស្តង់ដារនៃការរស់នៅ និងឱកាសសម្រាប់ជនមានពិការភាពនិងគ្រួសាររបស់ពួកគេត្រូវទទួលបានការឧបត្ថម្ភសាច់ប្រាក់ពីរដ្ឋ ដែលដោះស្រាយការចំណាយទាក់ទងនឹងពិការភាពខ្ពស់ជាងនេះ គឺជាការចាំបាច់។ បទពិសោធន៍អន្តរជាតិផ្តល់នូវជម្រើសអត្ថប្រយោជន៍ជាច្រើននៅក្នុងវដ្តជីវិតទាំងមូលក្នុងគោលបំណងប៉ាន់ស្មានលើការចំណាយបន្ថែមទាក់ទឹងនឹងពិការភាព ឧទាហរណ៍ តាមរយៈអត្ថប្រយោជន៍ពិការភាពរបស់កុមារ និងការទូទាត់ឯករាជ្យបុគ្គល។ ជាការប្រសើរបំផុត អត្ថប្រយោជន៍នេះនឹងមានជាសាកល - ផ្តល់ជូនដល់ជនមានពិការភាពទាំងអស់ ដោយសារបញ្ហាប្រឈមនៃការចំណាយបន្ថែមប៉ះពាល់ដល់ជនមានពិការភាពគ្រប់រូប។ នៅក្នុងប្រទេសកម្ពុជាដែលអនុវត្តនាពេលបច្ចុប្បន្ននេះ ប្រភេទនៃការទូទាត់អត្ថប្រយោជន៍ជាសាកលនេះក្នុងតម្លៃដែលបង្ហាញឱ្យឃើញពីការពិតនៃការចំណាយបន្ថែមទាក់ទងនឹងពិការភាពទំនងជាមានតម្លៃ ថ្លៃពេក និងស្មុគស្មាញខ្លាំងពេកមិនអាចបង្កើតឡើងបាន។ ជម្រើសដែលត្រូវបានអនុម័តនៅក្នុងប្រទេសដែលមានចំណូលទាប និងមធ្យមផ្សេងទៀត គឺផ្តល់អត្ថប្រយោជន៍ពិការភាពជាមួយនឹងតម្លៃថេរដែលមានការប្រែប្រួល ត្រូវបានកំណត់ស្របតាមកម្រិតភាពធ្ងន់ធ្ងរនៃពិការភាព។ បើទោះជាវិធីសាស្ត្រនេះមានដែនកំណត់ក៏ដោយ ក៏ការបង្កើតគម្រោងបែបនេះនឹងជាជំហាន ដំបូងដ៏សំខាន់ក្នុងការដោះស្រាយផលវិបាកសេដ្ឋកិច្ចនិងសង្គមដែលជនមានពិការភាពជាច្រើនបានជួបប្រទះនៅក្នុងប្រទេសកម្ពុជាទាំងមូល។[10]

---

[10]គំរូបង្ហាញបង្កើតឡើងដោយអង្គការ Development Pathways សម្រាប់ ACCESS អនុញ្ញាតឱ្យអ្នកប្រើប្រាស់ស្វែងយល់ និងមើលឃើញពីផលប៉ះពាល់សក្តានុពលនៃប្រព័ន្ធកិច្ចគាំពារសង្គមសម្រាប់ជនមានពិការភាព-ប្រកបដោយបរិយាបន្នសម្រាប់កម្ពុជា។ វាអាចត្រូវបានចូលប្រើប្រាស់នៅ **https://devpathways.shinyapps.io/access_disability_sptool/**